ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៦០ អនក្រ.បក

ក្រសួងបរិស្ថាន
ចូល លេខៈ 2882
ថ្ងៃទី 09 ខែ 05 ឆ្នាំ២០18
ម៉ោង 10:50

# អនុក្រឹត្យ
# ស្តីពី
# ការលើកទឹកចិត្តក្នុងការប្រតិបត្តិមេត្រីភាពបរិស្ថាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/ករម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៦/០៣ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៥/០១៩ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ ២០០៥ ដែលបានប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៣ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីស្តង់ដាកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្ដីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៥១៥/៤០៣ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៥ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
- បានឃើញអនុក្រឹត្យលេខ៥៩អនក្រ.បក ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
- បានឃើញអនុក្រឹត្យលេខ១៣៥ អនក្រ.បក ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ២៣៨ អនក្រ.បក ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៦ ស្ដីពីការបង្កើតមូលនិធិបរិស្ថាន និងសង្គម
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

# សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះមានគោលបំណងជំរុញការលើកទឹកចិត្តក្នុងការប្រតិបត្តិមេត្រីភាពបរិស្ថាន នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២.-**

អនុក្រឹត្យនេះមានគោលដៅដូចតទៅៈ

- លើកទឹកចិត្តដល់រូបវន្តបុគ្គល និងនីតិបុគ្គលក្នុងការប្រតិបត្តិមេត្រីភាពបរិស្ថានបានល្អស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន
- លើកទឹកចិត្តដល់ការផលិត ការប្រើប្រាស់បច្ចេកវិទ្យាទ្រទ្រង់បរិស្ថាន និងការប្រើប្រាស់ផលិតផលមេត្រីភាពបរិស្ថាន មានប្រភពចេញពីផលិតកម្ម សេវាកម្ម និងការគ្រប់គ្រងសកម្មភាពអាជីវកម្មនានាឆ្លើយតបទៅនឹងបមាណីយ និងគោលការណ៍នៃកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ និងការគ្រប់គ្រងធនធានធម្មជាតិដោយនិរន្តរភាព
- លើកកម្ពស់ការយល់ដឹង និងជំរុញការចូលរួមរបស់សាធារណជនក្នុងសកម្មភាពមេត្រីភាពបរិស្ថាន និងការថែរក្សាអត្តសញ្ញាណកម្មជាតិស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា៣.-**

អនុក្រឹត្យនេះមានវិសាលភាពគ្របដណ្ដប់ចំពោះ៖

១- រូបវន្តបុគ្គលដែលប្រតិបត្តិមេត្រីភាពបរិស្ថានបានល្អ

២- នីតិបុគ្គលដែលប្រតិបត្តិមេត្រីភាពបរិស្ថាន និងចូលរួមអនុវត្តបច្ចេកវិទ្យាទ្រទ្រង់បរិស្ថាន ការអភិវឌ្ឍដោយចីរភាព និងមានគណនេយ្យភាពសង្គមខ្ពស់

៣- រូបវន្តបុគ្គល ឬនីតិបុគ្គលដែលបានរួមចំណែកផ្ដល់វិភាគទានទ្រទ្រង់ដល់ការប្រតិបត្តិមេត្រីភាពបរិស្ថាន។

## ជំពូកទី២
## យន្តការអនុវត្តសកម្មភាពមេត្រីភាពបរិស្ថាន

**មាត្រា៤.-**

ក្រសួងបរិស្ថានមានអគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថានជាសេនាធិការ ត្រូវបំពេញតួនាទីជាស្ថាប័នបង្គោលក្នុងការចាត់ចែង រៀបចំបមាណីយមេត្រីភាពបរិស្ថាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តបមាណីយមេត្រីភាពបរិស្ថាន កៀរគរធនធាន និងផ្ដល់រង្វាន់លើកទឹកចិត្តមេត្រីភាពបរិស្ថានដល់រូបវន្តបុគ្គល និងនីតិបុគ្គលដែលប្រតិបត្តិតាមបមាណីយមេត្រីភាពបរិស្ថានបានល្អ ស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

បមាណីយមេត្រីភាពបរិស្ថានត្រូវកំណត់ដោយប្រកាសរបស់ក្រសួងបរិស្ថាន។

**មាត្រា៥.-**

ក្រសួងបរិស្ថានត្រូវរៀបចំយន្តការវាយតម្លៃការប្រតិបត្តិមេត្រីភាពបរិស្ថាន ដើម្បីផ្ដល់រង្វាន់លើកទឹកចិត្តមេត្រីភាពបរិស្ថាន។

យន្តការវាយតម្លៃការប្រតិបត្តិមេត្រីភាពបរិស្ថានត្រូវកំណត់ដោយប្រកាសរបស់ក្រសួងបរិស្ថាន។

**មាត្រា៦.-**

រូបវន្តបុគ្គលដែលត្រូវលើកទឹកចិត្ត និងផ្ដល់រង្វាន់មេត្រីភាពបរិស្ថាន ត្រូវមានសកម្មភាពពាក់ព័ន្ធនឹងកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការគ្រប់គ្រងធនធានប្រកបដោយនិរន្តរភាព និងការប្រើប្រាស់បច្ចេកវិទ្យាទ្រទ្រង់បរិស្ថាន។

**មាត្រា៧.-**

នីតិបុគ្គលដែលត្រូវលើកទឹកចិត្ត និងផ្ដល់រង្វាន់មេត្រីភាពបរិស្ថាន មានដូចខាងក្រោម៖

១- ក្រសួង ស្ថាប័នរដ្ឋ

២- គ្រឹះស្ថានសាធារណៈរដ្ឋបាល

៣- គ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ច
៤- សហគ្រាស និងក្រុមហ៊ុនឯកជន
៥- គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ
៦- គ្រឹះស្ថាននានាក្នុងវិស័យសិក្សាធិការ សាសនា និងគ្រឹះស្ថានផ្សេងៗទៀតដែលទ្រទ្រង់មេត្រីភាពបរិស្ថាន។

**មាត្រា៨.-**

នីតិបុគ្គលដូចមានចែងក្នុងមាត្រា៧ខាងលើ ត្រូវមានសកម្មភាពការងាររបស់ខ្លួន ដោយអនុលោមស្របតាមលក្ខខណ្ឌបច្ចេកទេស និងលក្ខណៈវិនិច្ឆ័យ ដូចខាងក្រោម៖

១- មានការប្រើប្រាស់បច្ចេកវិទ្យាទ្រទ្រង់បរិស្ថានសម្រាប់ផលិតកម្ម សេវាកម្ម និងការគ្រប់គ្រងសកម្មភាពអាជីវកម្មនានា
២- មានការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃផលិតផល សេវាផល និងប្រតិបត្តិផល ដែលទ្រទ្រង់បរិស្ថាន សេដ្ឋកិច្ច និងការលូតលាស់
៣- មានការលើកកម្ពស់ផលប្រយោជន៍សង្គម ធានាបាននូវសន្តិសុខ សុវត្ថិភាព សុខុមាលភាព និងផាសុកភាពសង្គម
៤- មានការលើកកម្ពស់កិច្ចគាំពារបរិស្ថាន ការអភិរក្សធនធានធម្មជាតិ ការការពារប្រព័ន្ធអេកូឡូស៊ី រួមមាន៖ ធនធានទឹក ដី បរិយាកាស និងជីវៈចម្រុះដោយរក្សាបាននូវបរិស្ថានស្អាត កាត់បន្ថយ ឬ លុបបំបាត់ការបំពុលបរិស្ថាន កាត់បន្ថយជាអតិប្បរមានូវផលប៉ះពាល់ចំពោះបរិស្ថាន និងធនធានធម្មជាតិ
៥- មានការលើកកម្ពស់ការថែរក្សាទំនៀមទម្លាប់ វប្បធម៌ ប្រពៃណី និងអត្តសញ្ញាណជាតិ ដោយរក្សាសិទ្ធិជាប្រពៃណីរបស់សហគមន៍ជនជាតិដើមភាគតិច និងអភិរក្សមរតកវប្បធម៌ផ្នែកចំណេះដឹងជាប្រពៃណីរបស់សហគមន៍មូលដ្ឋាននៅក្នុងផលិតកម្ម និងសេវាកម្មពាក់ព័ន្ធ។

**មាត្រា៩.-**

ក្រសួងបរិស្ថានត្រូវលើកកម្ពស់ការយល់ដឹងអំពីសកម្មភាពមេត្រីភាពបរិស្ថាន និងជំរុញចលនាប្រឡងប្រណាំងក្នុងការអនុវត្តសកម្មភាពមេត្រីភាពបរិស្ថាន។

## ជំពូកទី៣
## ប្រភេទសកម្មភាពមេត្រីភាពបរិស្ថាន

**មាត្រា១០.-**

ប្រភេទសកម្មភាពមេត្រីភាពបរិស្ថាន ដែលត្រូវអនុវត្តនៅក្នុងផលិតកម្ម ការផ្តល់សេវាកម្ម និងការងារគ្រប់គ្រងអាជីវកម្ម មានដូចខាងក្រោម៖

១- ការអនុវត្តប្រព័ន្ធបច្ចេកវិទ្យា ដែលមិនបង្កផលប៉ះពាល់ ឬ នាំមកនូវមហន្តរាយដល់បរិស្ថាន ក្នុងខ្សែសង្វាក់ផលិតកម្ម និងសេវាកម្មគ្រប់ប្រភេទ

២- ការប្រើប្រាស់វត្ថុធាតុដើមដែលទ្រទ្រង់ដល់និរន្តរភាពធនធានធម្មជាតិ និងបរិស្ថាន និងប្រើប្រាស់ដោយសន្សំសំចៃខ្ពស់ ឬ ប្រើប្រាស់វត្ថុធាតុដើមដែលអាចកែច្នៃចេញពីផលិតផលសម្រេច ឬ សំណល់

៣- ការប្រើប្រាស់ថាមពលកកើតឡើងវិញក្នុងផលិតកម្ម ដែលអាចកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ឬ កាត់បន្ថយការសាយភាយផ្សែងពុល

៤- ការគ្រប់គ្រងសំណល់បានល្អប្រសើរ ដោយមិនបង្កផលប៉ះពាល់ចំពោះបរិស្ថានជុំវិញ ឬ អនុវត្តបច្ចេកវិទ្យាស្អាត ដោយបម្លែង បន្សាបសារធាតុពុល ឬ សារធាតុកខ្វក់

៥- អនុវត្តនូវបច្ចេកវិទ្យាទ្រទ្រង់ដល់វិស័យបរិស្ថាន និងសង្គម

៦- ជំរុញការអនុវត្តកម្មវិធីទ្រទ្រង់បរិស្ថាន និងការចូលរួមធនធាន និងថវិកាក្នុងមូលនិធិបរិស្ថាន និងសង្គម។

## ជំពូកទី ៤
## ការវាយតម្លៃសកម្មភាពប្រតិបត្តិមេត្រីភាពបរិស្ថាន

**មាត្រា១១.-**

ក្រសួងបរិស្ថានត្រូវរៀបចំការវាយតម្លៃសកម្មភាពប្រតិបត្តិមេត្រីភាពបរិស្ថានជាទៀងទាត់តាមកាលកំណត់ដូចខាងក្រោម៖

- ចំពោះរូបវន្តបុគ្គល៖ ការវាយតម្លៃសកម្មភាពប្រតិបត្តិមេត្រីភាពបរិស្ថាន ត្រូវធ្វើឡើងមួយឆ្នាំ (០១) ម្តង
- ចំពោះនីតិបុគ្គល៖ ការវាយតម្លៃសកម្មភាពប្រតិបត្តិមេត្រីភាពបរិស្ថាន ត្រូវធ្វើឡើងរៀងរាល់ពីរឆ្នាំ(០២) ម្តង។

សូចនាករ និងលក្ខណៈវិនិច្ឆ័យសម្រាប់វាយតម្លៃសកម្មភាពប្រតិបត្តិមេត្រីភាពបរិស្ថាន ត្រូវកំណត់ដោយប្រកាសស្តីពីបមាណីយមេត្រីភាពបរិស្ថាន។

**មាត្រា១២.-**

រូបវន្តបុគ្គល និងនីតិបុគ្គលដែលប្រតិបត្តិមេត្រីភាពបរិស្ថានបានល្អ នឹងត្រូវទទួលរង្វាន់លើកទឹកចិត្តមេត្រីភាពបរិស្ថាន ដោយឆ្លងកាត់ការវាយតម្លៃសកម្មភាពប្រតិបត្តិមេត្រីភាពបរិស្ថាន។

## ជំពូកទី ៥
## ប្រភេទរង្វាន់លើកទឹកចិត្តមេត្រីភាពបរិស្ថាន

**មាត្រា១៣.-**

ប្រភេទរង្វាន់លើកទឹកចិត្តមេត្រីភាពបរិស្ថាន ត្រូវបានកំណត់ដូចខាងក្រោម៖

១- ប័ណ្ណសរសើរមេត្រីភាពបរិស្ថាន

២- វិញ្ញាបនបត្រទទួលស្គាល់មេត្រីភាពបរិស្ថាន

៣- ស្លាកសញ្ញាមេត្រីភាពបរិស្ថាន និង

៤- មេដាយ និងពានរង្វាន់មេត្រីភាពបរិស្ថាន។

**មាត្រា១៤.-**

ប្រភេទរង្វាន់ ការរចនា និងគំរូនៃប្រភេទរង្វាន់លើកទឹកចិត្តមេត្រីភាពបរិស្ថាន ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងបរិស្ថាន។

## ជំពូកទី៦
## ប្រភពធនធានហិរញ្ញប្បទាន

**មាត្រា១៥.-**

ក្រសួងបរិស្ថានត្រូវលើកទឹកចិត្តដល់សហគ្រិន វិនិយោគិន សប្បុរសជន និងដៃគូពាក់ព័ន្ធ ដែលស្រលាញ់បរិស្ថាន ផ្តល់វិភាគទាន ឬ សហហិរញ្ញប្បទានដល់ការប្រតិបត្តិមេត្រីភាពបរិស្ថាន។

ក្រសួងបរិស្ថានមានសិទ្ធិទទួល និងប្រើប្រាស់វិភាគទានពីសហគ្រិន វិនិយោគិន សប្បុរសជន និងដៃគូពាក់ព័ន្ធ ក្នុងកិច្ចដំណើរការនៃការលើកទឹកចិត្តក្នុងការប្រតិបត្តិមេត្រីភាពបរិស្ថាន។

**មាត្រា១៦.-**

ក្រសួងបរិស្ថានមានសិទ្ធិស្នើសុំថវិកាពីមូលនិធិបរិស្ថាន និងសង្គម មកប្រើប្រាស់ជាប្រភពហិរញ្ញប្បទានសម្រាប់ការលើកទឹកចិត្តក្នុងការប្រតិបត្តិមេត្រីភាពបរិស្ថាន។

## ជំពូកទី៧
## អវសានប្បញ្ញត្តិ

**មាត្រា១៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា១៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ៕

ថ្ងៃ អង្គារ ៩ រោច ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៨ ខែឧសភា ឆ្នាំ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

**សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី** សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**សាយ សំអាល់**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ